00920478

E282/2

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 13 / 06 / 2013
ម៉ោង (Time/Heure): 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**សាធារណៈ / Public**

**អង្គជំនុំជម្រះសាលាដំបូង**

ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣

**ជូនចំពោះ:** គ្រប់ភាគីនៃសំណុំរឿង ០០២

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា និងសំណើរបស់ ខៀវ សំផន អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ស្តីពីសារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិក (E282 និង E282/1, E290 និង E290/1)

1. អង្គជំនុំជម្រះបានទទួលសំណើមួយពីសហព្រះរាជអាជ្ញាស្នើសុំដាក់ជូនអង្គជំនុំជម្រះនូវភស្តុតាងថ្មីៗដែលជាសារទូរលេខតាមផ្លូវទូតចំនួន ២៦ ដែលបានផ្ញើរវាងស្ថានទូតសហរដ្ឋអាមេរិក និង ក្រសួងការបរទេសសហរដ្ឋអាមេរិកនៅចន្លោះឆ្នាំ ១៩៧៣ ដល់ឆ្នាំ ១៩៧៥ (ឯកសារ E282)។ មេធាវីការពារក្តី ខៀវ សំផន ជំទាស់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ដោយសំអាងលើហេតុផលថាសារទូរលេខទាំងនោះពុំសមស្របក្នុងការបញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាងឡើយ និងជាការរំលោភលើសិទ្ធិរបស់មេធាវីការពារក្តីក្នុងការសួរដេញដោល។ មេធាវី ក៏បានអះអាង

ផងដែរថា ឯកសារ E282.1.7 គឺមិនមានភាពពាក់ព័ន្ធទៅនឹងសំណុំរឿងនេះឡើយ (ឯកសារ E282/1)។

2. អង្គជំនុំជម្រះក៏បានទទួលសំណើមួយផងដែរពីមេធាវីការពារក្តី ខៀវ សំផន ដែលស្នើសុំដាក់ជូនអង្គជំនុំជម្រះនូវភស្តុតាងថ្មីៗ ដែលរួមមានសារទូរលេខតាមផ្លូវទូតចំនួន ១៤ ដែលបានផ្ញើរវាងស្ថានទូតសហរដ្ឋអាមេរិក និងក្រសួងការបរទេសសហរដ្ឋអាមេរិក នៅចន្លោះពីឆ្នាំ ១៩៧៣ ដល់ឆ្នាំ ១៩៧៥ និងពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០០៧ (ឯកសារ E290)។ សហព្រះរាជអាជ្ញាបានជំទាស់ទៅលើការទទួលយកនូវសារទូរលេខចំនួន ០២ ដែលបានធ្វើនៅចន្លោះឆ្នាំ ២០០៦ ដល់ឆ្នាំ ២០០៧ (ឯកសារ E290.1.13 និង E290.1.14) ព្រោះសារទូរលេខទាំងនោះមិនមានភាពពាក់ព័ន្ធ មានភាពច្រំដែល ហើយពុំសមស្របក្នុងការបញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង។ សហព្រះរាជអាជ្ញាមិនបានជំទាស់ទៅនឹងការទទួលយកនូវសារទូរលេខចំនួន ១២ ផ្សេងទៀត ដែលបានធ្វើនៅចន្លោះពីឆ្នាំ ១៩៧៣ និង ១៩៧៥ (ឯកសារ E290/1) នោះឡើយ ។

3. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកនូវភស្តុតាងថ្មីដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត ប្រសិនបើភស្តុតាងនោះបំពេញផងដែរនូវបទដ្ឋាននៃការវាយតម្លៃ*បឋម*នូវភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាពដែលតម្រូវឱ្យមាននៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឱ្យពិនិត្យភស្តុតាង បើអង្គជំនុំជម្រះយល់ឃើញ*ជាអាទិ៍* ថាភស្តុតាងទាំងនោះមិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ ឬមិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង។ ជាធម្មតា ភាគីដែលស្នើសុំត្រូវធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថា ភស្តុតាងដែលស្នើសុំនោះពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ ឬមិនអាចរកបានទោះបីជាមានការបំពេញការងារដោយយកចិត្តទុកដាក់ពិតប្រាកដក៏ដោយ។ អង្គជំនុំជម្រះធ្លាប់បានចង្អុលបង្ហាញពីមុនថា ឯកសារដែលមិនត្រូវបានដាក់បញ្ចូលនៅក្នុងបញ្ជីឯកសារដំបូងរបស់ភាគី អនុលោមតាមវិធាន ៨០(៣) នៃវិធានផ្ទៃក្នុង ឯកសារនោះបង្កើតបានជាឯកសារថ្មី ដោយត្រូវស្ថិតនៅក្រោមលក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៤)នៃវិធានផ្ទៃក្នុង ប៉ុន្តែ ឯកសា រនោះអាចត្រូវបានទទួលយក ប្រសិនបើការទទួលយកឯកសារនេះផ្តល់ផលប្រយោជន៍ដល់យុត្តិធម៌ (ឯកសារ E190 កថាខណ្ឌ ១៩-២១)។

4. លើកលែងតែឯកសារ E290.1.13 (សរសេរក្នុងឆ្នាំ ២០០៧ និងនៅតែចាត់ថ្នាក់ជាប្រភេទជាឯកសារសម្ងាត់) អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ឯកសារដែលបានស្នើសុំទាំងអស់អាចរកបាននៅមុនពេលចាប់ផ្ដើមជំនុំជម្រះ ដោយសារតែសារទូរលេខតាមផ្លូវទូតទាំងអស់ លើកលែងតែសារទូរលេខតែមួយប៉ុណ្ណោះ ត្រូវបានដាក់ឱ្យរកមើលបាន និងបញ្ចេញជាសាធារណៈដោយក្រសួងការបរទេសសហរដ្ឋអាមេរិកនៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៥ ឬថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០០៦ ។ សារទូរលេខដែលនៅសល់ត្រូវបានសរសេរនៅក្នុងខែ កក្កដា ឆ្នាំ ២០០៦ និងជាប្រភេទឯកសារសាធារណៈ (ឯកសារ E290.1.14)។

5. អង្គជំនុំជម្រះទទួលស្គាល់ថា សារទូរលេខដែលសហព្រះរាជអាជ្ញាបានស្នើសុំមិនអាចរកបានកាលពីមុនឡើយ ទោះបីជាមានការបំពេញការងារដោយយកចិត្តទុកដាក់ពិតប្រាកដក៏ដោយ ដោយសារតែពុំមានសារទូរលេខណាមួយ គឺជាផ្នែកនៃសំណើពីមុនរបស់ ក.ស.ច.ស ស្នើសុំដាក់បញ្ចូលទៅក្នុងសំណុំរឿងនូវសារទូរលេខដែលទទួលបានកាលពីមុនពីក្រសួងការបរទេសសហរដ្ឋអាមេរិក ដែលស្ថិតនៅក្នុងអំឡុងពេលដូចគ្នានោះឡើយ (ឯកសារ E282 កថាខណ្ឌ ៤)។ លើសពីនេះទៀត សារទូរលេខទាំងនោះ មិនអាចរកមើលបានឡើយតាមរយៈគេហទំព័រ WikiLeaks ដែលជាអង្គការមួយមិនរកប្រាក់កម្រៃដែលផ្សព្វផ្សាយតាមប្រព័ន្ធអ៊ិនធើណែតនូវព័ត៌មានសម្ងាត់ ឬជាសាធារណៈ (ប៉ុន្តែព័ត៌មានទាំងនោះមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅឡើយ) ពីប្រភពអនាមិក ដោយសារតែកាលពីមុនឯកសារទាំងនេះអាចរកមើលបាននៅក្នុង "ក្រុមឯកសារដែលក្នុងនោះមានសារទូរលេខតាមផ្លូវទូតចំនួនជាងមួយលានប្រាំពីរសែន (១,៧លាន) 'ក្នុងទម្រង់មិនទាន់រៀបរយ និងមិនមានការរៀបចំត្រឹមត្រូវតែប៉ុណ្ណោះ'" (ឯកសារ E282 កថាខណ្ឌ ៣)។ អង្គជំនុំជម្រះយល់ឃើញថា សហព្រះរាជអាជ្ញាក្រោយមកបានបំពេញការងារដោយយកចិត្តទុកដាក់ពិតប្រាកដក្នុងការស្វែងរក និងបង្ហាញភស្តុតាងថ្មីនេះ នៅពេលដែល WikiLeaks បានបង្កើតប្រព័ន្ធទិន្នន័យដែលអាចស្រាវជ្រាវបាន នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ ២០១៣ (ឯកសារE282 កថាខណ្ឌ ៣) បន្ទាប់ពីនោះមក សហព្រះរាជអាជ្ញាបានដាក់សំណើរបស់ខ្លួនស្នើសុំដាក់ភស្តុតាងថ្មីនេះនៅចំពោះមុខអង្គជំនុំជម្រះ នៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៣។

6. ផ្ទុយទៅវិញ មេធាវីការពារក្ដី ខៀវ សំផន ពុំបានផ្ដល់ការពន្យល់សមហេតុផលណាមួយថាតើហេតុអ្វីបានជាសារទូរលេខដែលបានស្នើសុំចំនួន ១៤ នោះ មិនអាចរកបាន ទោះបីជាមានការយកចិត្ត

ទុកដាក់ពិតប្រាកដ នៅចន្លោះឆ្នាំ ២០០៥/២០០៦ ដល់ខែ មេសា ឆ្នាំ ២០១៣ នៅពេលដែល WikiLeaks បានបង្កើតប្រព័ន្ធទិន្នន័យដែលអាចស្រាវជ្រាវបាន ដែលក្នុងអំឡុងពេលនោះ សារទូរលេខចំនួនដប់ពីរ ត្រូវបានកំណត់ថាមិនមែនជាឯកសារសម្ងាត់តទៅទៀតទេ ហើយសារទូរលេខមួយតែងតែស្ថិតជាប្រភេទឯកសារសាធារណៈ។ ពួកគាត់ក៏ពុំបានពន្យល់ផងដែរអំពីការពន្យារពេលក្នុងការដាក់សំណើរបស់ខ្លួនរយៈពេលជិតពីរខែ បន្ទាប់ពីការបង្កើតប្រព័ន្ធទិន្នន័យដែលអាចស្រាវជ្រាវបានរបស់ WikiLeaks។ នៅក្នុងកាលៈទេសៈទាំងនេះ មេធាវីការពារក្តី ខៀវ សំផន ពុំបានបំពេញនូវលក្ខខណ្ឌតម្រូវដ៏តឹងរ៉ឹងនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងឡើយ។

7. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ទៀតថា សារទូរលេខដែលបានស្នើសុំទាំងអស់មានប្រភពចេញមកពីគេហទំព័រ WikiLeaks ជាជាងចេញពីប្រភពផ្លូវការរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក។ ហេតុដូច្នេះ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានបានថា សម្ភារៈដែលទទួលបានពីគេហទំព័រ Wikileaks មានយថាភាពបានឡើយ។ ទោះបីជាភាគីអាចស្វះស្វែងដើម្បីទទួលបានសំណៅថតចម្លងដែលមានយថាភាពនៃសារទូរលេខដែលបានស្នើសុំទាំងនោះពីប្រភពផ្លូវការ និងដាក់ឯកសារទាំងនោះទៅក្នុងសំណុំរឿងយ៉ាងណាក៏ដោយ ក៏ដំណើរការនេះហាក់ដូចជាអូសបន្លាយពេលយូរ។ ដូច្នេះ ភស្តុតាងដែលបានស្នើសុំនោះពុំបានបំពេញនូវលក្ខខណ្ឌតម្រូវរបស់វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងអំពីភាពអាចរកបានក្នុងរយៈពេលសមស្របណាមួយនោះឡើយ។

8. អង្គជំនុំជម្រះសាលាដំបូងក៏បានពិចារណាឃើញផងដែរថា សារទូរលេខតាមផ្លូវទូតចំនួន ២៦ ដែលសហព្រះរាជអាជ្ញាបានស្នើសុំ និងសារទូរលេខចំនួន ០៨ ដែលមេធាវីការពារក្តី ខៀវ សំផន បានស្នើសុំ (E290.1.1, E290.1.2, E290.1.3, E290.1.4, E290.1.5, E290.1.8, E290.1.9 និង E290.1.10) គឺជាការស្នើសុំជាន់គ្នា ព្រោះសារទូរលេខទាំងនោះត្រូវបានស្នើសុំក្នុងគោលបំណងសំខាន់គឺដើម្បីបញ្ជាក់អះអាងនូវសារៈតាភស្តុតាងដែលមាននៅក្នុងសំណុំរឿងរួចហើយ ទាក់ទិននឹងកាលៈទេសៈនានា ដែលកើតមាននៅប្រទេសកម្ពុជានៅចន្លោះឆ្នាំ ១៩៧៣ ដល់ឆ្នាំ ១៩៧៥។

9. សេចក្តីដកស្រង់ចេញពីសារទូរលេខចំនួន ០៤ ដែលមេធាវីការពារក្តី ខៀវ សំផន បានស្នើសុំនោះគឺទាក់ទងនឹងតួនាទី និងសិទ្ធិអំណាចរបស់លោក ខៀវ សំផន ទាំងនៅមុន និងក្រោយឆ្នាំ ១៩៧៥ (E290.1.5, E290.1.6, E290.1.11 និង E290.1.12)។ តាមរយៈការទទួលស្គាល់ដោយផ្ទាល់របស់

មេធាវីការពារក្តី សម្រង់ទាំងនេះបានរួមបញ្ចូលនូវសក្ខីកម្មដែលមានរួចហើយនៅចំពោះមុខអង្គជំនុំ-ជម្រះ (ឯកសារ E290 កថាខណ្ឌ ១៩ និង ២១)។ ពេលដែលសម្រង់នៃសារទូរលេខផ្សេងទៀត គាំទ្រ តម្រុយភស្តុតាងទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ខៀវ សំផន (E290.1.1, E290.1.5, E290.1.6 និង E290.1.7) ភស្តុតាងសំខាន់ៗត្រូវបានដាក់បង្ហាញរួចហើយនៅចំពោះមុខអង្គជំនុំជម្រះ ពាក់ព័ន្ធនឹងបញ្ហានេះ ហើយសាក្សីផ្សេងទៀតពាក់ព័ន្ធនឹងអត្តចរិតនោះនឹងត្រូវមកផ្តល់សក្ខីកម្ម (ឯកសារ E288)។ ហេតុនេះ សម្រង់ពីសារទូរលេខទាំងនោះគឺមានលក្ខណៈជាន់គ្នា (ឯកសារ E290 កថាខណ្ឌ ១៦)។

10. ចុងក្រោយ មេធាវីការពារក្តី ខៀវ សំផន ស្នើដាក់ឯកសារ E290.1.13 និង E290.1.14 ដើម្បីជាភស្តុតាងអំពីការជ្រៀតជ្រែកផ្នែកនយោបាយទៅក្នុងកិច្ចការរបស់ អ.វ.ត.ក ក្នុងការគាំទ្រការចោទប្រកាន់អំពីភាពលម្អៀងផ្នែកនយោបាយរបស់ព្រះរាជអាជ្ញាជាតិពីររូប ការមិនសហការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា អំពើពុករលួយក្នុងការជួលបុគ្គលិកជាតិ ការលេចធ្លាយព័ត៌មានសម្ងាត់ទៅឯលំមន្ត្រីស្ថានទូតសហរដ្ឋអាមេរិកពាក់ព័ន្ធនឹងចំនួន និងអត្តសញ្ញាណរបស់ជនសង្ស័យដែលសហចៅក្រមស៊ើបអង្កេតបានធ្វើការស៊ើបអង្កេត និងការជ្រើសរើសលោក Stephen HEDER ដោយសហព្រះរាជអាជ្ញា។ ព័ត៌មានដែលពួកគាត់ទទួលបានមានលក្ខណៈទូទៅ ហើយមេធាវីការពារក្តី ខៀវ សំផន ពុំបានបង្ហាញអំពីភាពពាក់ព័ន្ធនៃបញ្ហាទាំងនេះទៅនឹងការទទួលខុសត្រូវរបស់ជនជាប់ចោទដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១ ឬក៏អង្គហេតុដែលចោទជាបញ្ហាសម្រាប់ការជំនុំជម្រះឡើយ។

11. ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា សម្ភារៈដែលបានស្នើសុំ ពុំបានបំពេញបទដ្ឋាននៃការវាយតម្លៃ*បឋម*នៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាពដែលតម្រូវឲ្យមាននៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងនោះឡើយ។ អង្គជំនុំជម្រះបដិសេធសំណើរបស់សហព្រះរាជអាជ្ញា និងសំណើរបស់លោក ខៀវ សំផន ដោយផ្អែកលើមូលហេតុនៃការមិនអាចរកបាននូវសារទូរលេខទាំងនោះ (សំណៅដែលមានបញ្ជាក់យថាភាព) ក្នុងរយៈពេលសមស្របណាមួយ (វិធាន ៨៧(៣)(ខ) នៃវិធានផ្ទៃក្នុង)។ អង្គជំនុំជម្រះបដិសេធលើសំណើទាំងនេះផងដែរ ដោយផ្អែកលើមូលដ្ឋានថាសារទូរលេខដែលបានស្នើសុំទាំងនោះគឺមានភាពជាន់គ្នាជាមួយនឹងភស្តុតាងដែលមានរួចហើយនៅក្នុងសំណុំរឿង និង/ឬមិនជាប់ពាក់ព័ន្ធ (វិធាន ៨៧(៣)(ក) នៃវិធានផ្ទៃក្នុង)។

12. សេចក្ដីសម្រេចនេះគឺជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងឯកសារ E282, E282/1, E290 និង E290/1។